**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២០៩
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១
**សាលដីកា**
លេខ:១៤៦
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ............... ជាចៅក្រម
៤-លោក ............... ជាចៅក្រមរបាយការណ៍
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ................

**តំណាងមហាអយ្យការ**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៤(ឈ) ចុះថ្ងៃទី៣១ខែមិថុនា ឆ្នាំ២០០១ នា នៃសំណុំរឿងលេខ៧២២ ចុះថ្ងៃទី២១ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ទណខ ម្ចាស់បណ្តឹងសាទុក្ខ ភេទស្រី អាយុ៥២ឆ្នាំជាតិខ្មែរទីលំនៅសព្វថ្ងៃ ក្រុមទី១០ មណ្ឌល២ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។ ឪពុកឈ្មោះទី រស់ (ស ) ម្តាយឈ្មោះ ស្រី ណន (ស) ប្តីឈ្មោះលោក ផេង ហុត ។

មានមេធាវី លោក សអរ

និងចុងចម្លើយឈ្មោះ មដ (ចុងបណ្តឹងសាទុក្ខ) ភេទស្រីអាយុ៥១ ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិ៤ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ម៉ក់ ម៉ុត (ស)ម្តាយឈ្មោះប៊ូ ខូវ (ស) ប្តីឈ្មោះ សុទ្ធ សឹន ។

អំពីវិវាទ: ប្តឹងទាមទារដីទំហំ ៣០ម x ៤០ម

បានឃើញបណ្តឹងសាទុក្ខលេខ២០២ ចុះថ្ងៃទី០៥ខែមិថុនាឆ្នាំ២០០១ របស់លោក សអរ ជាមេធាវីតំណាងឱ្យអ្នកស្រី ទណខ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៧៤(ឈ) ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២០៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៣-១១-៩៩ របស់អ្នកស្រីទណខថា ខ្លួនបានគ្រប់លើដីទំនាស់ទំហំ ៣០ម$\times$៤០ម តាមប័ណ្ណកម្មសិទ្ធិលេខ$A_3$0124 ចុះថ្ងៃទី២៨-១១-៩៥ តាំងពីយូយារមកហើយ គឺមិនដែលឃើញអ្នកស្រី មជ មកតវ៉ាឡើយ ។ ឥឡូវនេះ ស្រាប់តែឃើញតំណាង អ្នកស្រី ម៉ាក់ ជឹម មកធ្វើរបងលើដីរបស់ខ្លួន មិនតែប៉ុណ្ណោះ ភាគីតំណាងចុងចម្លើយថែមទាំងបានអះអាងថា ជាដីរបស់ មជ និងមានប្លង់ប័ណ្ណកម្មសិទ្ធិទៀតផង ។ ដោយហេតុនេះ ទើបខ្លួនប្តឹងមកតុលាការ ដើម្បីទាមទារយកដីរបស់ខ្លួន ពីចុងចម្លើយ មកគ្រប់គ្រងតាមប័ណ្ណកម្មសិទ្ធិ ដែលខ្លួនបានគ្រប់គ្រងកន្លងមក ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦២ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ របស់ តុលាការក្រុងព្រះសីហនុ សម្រេចចំពោះមុខគូភាគី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៣-១១-៩៩ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ពន ០០១២០៤ ចុះថ្ងៃទី២៨-១១-៩៥ ដែលផ្ទេរពីឈ្មោះ ឈឹម ហ៊ មកអ្នកស្រី ទណខ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- ប្រគល់ដីទំនាស់ដែលមានទំហំ៣០ម$\times$៤០ម ស្ថិតនៅមណ្ឌល០១ សង្កាត់៣ ខណ្ឌមិត្តភាពក្រុងព្រះសីហនុ ឱ្យទៅអ្នកស្រី ទណខ គ្រប់គ្រងជាកម្មសិទ្ធិ ចាប់តាំងពីពេលសាលក្រមក្លាយជាសាលក្រមស្ថាពរតទៅ ។

៤-ឱ្យចុងចម្លើយសងសំណង និងជម្ងឺចិត្ត ទៅដើមចោទជាប្រាក់ចំនួន៥០០០ដុល្លារ(ប្រាំពាន់ដុល្លាអាមេរិក) សំណើលើសពីនេះ ត្រូវលើកចោល និងឱ្យចុងចម្លើយរុះរើសំណង់ ដែលមាននៅ លើដីទំនាស់ ចាប់តាំងពីពេលសាលក្រមនេះ ក្លាយទៅជាសាលក្រមស្ថាពរ តទៅ ។

៥-ឱ្យអ្នកស្រី មជ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១៨០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០រៀល រង្វាន់អ្នករត់ដីកាកោះចំនួន៥០០០រៀល សរុប៧០០០រៀល ប្រាក់នេះ បានកាត់យកពីប្រាក់៧០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ កាលបើផុតឧទ្ធរណ៍ ទើបឱ្យចុងចម្លើយ សងទៅដើមចោទវិញ និងឱ្យអ្នកស្រីមជ បង់ពន្ធសមាមាត្រ១%លើតម្លៃដី(ដីទំនាស់) ជាក់ស្តែង ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០% បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ប្រាក់ពន្ធ សមាមាត្រនេះ ត្រូវឱ្យដើមចោទ បង់មុនដែរ ទើបតម្រូវឱ្យចុងចម្លើយសងទៅដើមចោទវិញ ។

៦- សាលក្រមនេះ ជំនុំជំរះ ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ របស់អ្នកស្រីមជ ប្តឹងមិនសុខចិត្ត នឹងសាលក្រមរដ្ឋប្បវេណីលេខ៦២ ចុះថ្ងៃទី៣១ខែកក្កដា ឆ្នាំ២០០០ របស់តុលាការក្រុងព្រះសីហនុ លើ សេចក្តីសម្រេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៧៤(ឈ) ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០១ របស់សាលា ឧទ្ធរណ៍ សម្រេចចំពោះមុខមេធាវីតំណាងដើមចោទ និងតំណាងចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្តី សម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៥៨ ចុះថ្ងៃទី៣០-០៨-២០០០ របស់ឈ្មោះ មជ ទុកជាត្រឹម ត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមដ្ឋប្បវេណីលេខ៦២ ចុះថ្ងៃទី២៨-០៨-២០០០ របស់តំលាការក្រុង ព្រះ សីហនុ ចោលជាអសារបង់ ។

៣- រក្សាសិទ្ធិកម្មសិទ្ធិលើដីលំនៅដ្ឋានទំហំ១២អា ស្ថិតនៅមណ្ឌល១ សង្កាត់លេខ៣ ខណ្ឌ មិត្តភាព ក្រុងព្រះសីហនុ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ$A_3$១៩៧ ចុះថ្ងៃទី១០-០៦- ៩៣ ជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ មជ ជាចុងចម្លើយតទៅ ។

៤- ទុកសិទ្ធិឱ្យដើមចោទឈ្មោះ ទណខ ប្តឹងទារប្រាក់ពីអ្នកពាក់ព័ន្ធ ក្នុងការលក់ដីឱ្យខ្លួន។

៥- បង្គាប់ឱ្យឈ្មោះ មជ សងប្រាក់ថ្លៃរុះរើសំណង់អនាធិបតេយ្យ ចេញពីដីទំនាស់នេះចំនួន ១៥០០ដុល្លារ ឱ្យទៅឈ្មោះ ទណខ វិញនៅពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

៦- រឹបអូសប្រាក់ប្រដាប់ក្តី ដែលឈ្មោះ មជ បានបង់រួចហើយ គឺពន្ធហ្នឹង និងពន្ធចុះ បញ្ជីក្តី២៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ៥០០០រៀល សរុប១៣០០០រៀល និងឱ្យឈ្មោះ ទណខ បង់ពន្ធ សមា មាត្រទៅឈ្មោះមជ វិញ ជាក្រោយ រួមទាំងប្រាក់ប្រដាប់ក្តី១៣០០០រៀល ផង ។

៧- សាលដីកានេះដំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីតំណាងដើមចោទ និង តំណាងចុងចម្លើយ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ២០២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់លោកសអរ ជា មេធាវីតំណាងឲ្យអ្នកស្រី ទណខ ប្តឹងមិនសុខចិត្តនឹងសាលដីការរដ្ឋប្បវេណីលេខ៧៤ (ឈ)ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍លើគ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញ សារណាការពារ ចុះថ្ងៃទី០៧-០៨-២០០១ របស់មេធាវីលោកសអរ

បានឃើញ សារណាតប ចុះថ្ងៃទី២៩-០៩-២០០១ របស់លោក សុទ្ធ សីន និង ប្រពន្ធ ឈ្មោះ មជ

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ

-សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ បានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមទាំងទម្រង់ ទាំងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណា របស់អ្នកស្រី ទណខ

បានស្តាប់ចម្លើយរបស់លោក សុទ្ធ សឺន ឆ្លើយថា ចំពោះសារណារបស់ ទណខ ខ្លួនបានធ្វើសារណាតបរួចហើយដីនេះ បានទទួលប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ពីសុរិយោដីក្រុងរួចហើយ ដូចមាន លិខិតបញ្ជាក់ស្រាប់ថា ដំឡូត៍នេះមិនជាន់គ្នាទេ មានព្រំប្រទល់ច្បាស់លាស់ផង ប្លង់ខ្លួនមានជាប់ដីបីភាគី ទៀតបានធ្វើប្លង់រួចហើយ ។ ដីខ្លួនជាដីគំពោងផ្លូវទី១ ដីខ្លួនធ្វើប័ណ្ណកម្មសិទ្ធិនៅឆ្នាំ៩៣ ហើយគេបន្លំយ៉ាងច្បាស់ ដាក់ព្រំប្រទល់ខុសគ្នា យើងឃើញយ៉ាងច្បាស់តាមរយៈរូបថតព្រំប្រទល់ជាប់ដីនេះមាន លឹម គៀនហោ ជា គីមអេង តាមប្លង់នេះបង្ហាញថា ដីទំនាស់ ជាដីរបស់ខ្លួនមានប្លង់នេះជាភស្តុតាងដែលអាចឱ្យយើង ពិចារណាបាន ប័ណ្ណកម្មសិទ្ធិធ្វើត្រឹមត្រូវ តាមច្បាប់ឥតបន្លំ ។ ភាគីដើមចោទទេ ដែលបំពាបំពានរំលោភលើ សិទ្ធិកម្មសិទ្ធិរបស់ខ្លួន ។

សាលាឧទ្ធរណ៍សម្រេចត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយសូមតុលាការកំពូលរកយុត្តិធម៌ ។

បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវីលោក សអរ បញ្ជាក់ថា

ដូចមានសារណារបស់ខ្ញុំ ជូនក្រុមប្រឹក្សាជ្រាបហើយ ខ្ញុំយល់ថា តុលាការក្រុងព្រះសីហនុ មានភស្តុតាងគ្រប់គ្រាន់ហើយ ដែលសម្រេចប្រគល់ដីឱ្យកូនក្តី ខ្ញុំមានអាជ្ញាធរមូលដ្ឋានរហូត ឃឹម បូរផង បញ្ជាក់ថា ដី ទណខ មិនជាន់លើដី មជ ទេ មានសាលក្រមតុលាការក្រុងព្រះសីហនុស្រាប់ ខ្ញុំសុំឱ្យសាលាឧទ្ធរណ៍ហៅសាក្សីមកសួរតែសាលាឧទ្ធរណ៍ មិនធ្វើតាមសំណើខ្ញុំ នេះជាការខុសឆ្គង។

ការបញ្ជាក់របស់មន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រុងព្រះសីហនុ ជាភស្តុតាងឱ្យសាលាឧទ្ធរណ៍សម្រេចបានហើយ តែសាលាឧទ្ធរណ៍សម្រេចទាំងអគតិ ខ្ញុំសូមតុលាការកំពូល តម្កល់សាលក្រមតុលាការក្រុងព្រះសីហនុ និង បដិសេធសាលដីកាសាលាឧទ្ធរណ៍ បង្វិលឱ្យសង្កេតជាថ្មី ដើម្បីកូនក្តីខ្ញុំបានគ្រប់គ្រងដីទំនាស់នេះជាកម្មសិទ្ធិតទៅ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយករណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប័ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពារមេធាវីដើមចោទ

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

<u>តុលាការកំពូល</u>

យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់លោកសអរ មេធាវីដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការលើកឡើងរបស់លោកសអរ មេធាវីការពារឱ្យ អ្នកស្រី ទណខ ក្នុងសារណា ចុះថ្ងៃទី០៧-០៨-០១ ថា ដោយយោងតាមការអង្កេតរបស់ខ្លួន និងយោងតាមឯកសារ និង ចម្លើយចំពោះមុខតុលាការក្រុងព្រះសីហនុរបស់សាក្សី ព្រមទាំងលិខិតសំអាងផ្សេងៗរបស់ អាជ្ញាធរក្រុងព្រះសីហនុ បញ្ជាក់ច្បាស់ថា អ្នកស្រី ទណខ ជាម្ចាស់កម្មសិទ្ធិស្របតាមលក្ខខ័ណ្ឌច្បាប់ លើដីទំនាស់ដែលមានប័ណ្ណកម្មសិទ្ធិលេខពន.០០១២០៤ ចុះថ្ងៃទី២៨-១១-៩៥ ប្រាកដមែននោះ គឺជាការពុំត្រឹមត្រូវឡើយពីព្រោះថា

-ចុងចម្លើយអ្នកស្រីម៉ាក់ ជឹម បានទទួលដីទំនាស់ តាមការបែងចែករបស់អាជ្ញាធរក្រុងព្រះសីហនុ ព្រមទាំងមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខA3197ចុះថ្ងៃទី១០-៦-៩៣ដែលមានព្រំប្រទល់ដីត្រឹមត្រូវ ។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ពន.០០១២០៤ ចុះថ្ងៃទី២៨-១១-៩៥ របស់ដើមចោទអ្នកស្រី មិន ណៃខេង ត្រូវបានអាជ្ញាធរក្រុងព្រះសីហនុ និងនាយកដ្ឋានសុរិយោដីចេញឱ្យនៅឆ្នាំ១៩៩៥ គឺក្រោយប័ណ្ណសំគាល់សិទ្ធិរបស់អ្នកស្រី មជ ហើយមានព្រំប្រទល់ដី ពុំច្បាស់លាស់ខុសពីទីតាំងដីរបស់អ្នកស្រី ម៉ក់ ជឹម ។

-យល់ឃើញថា ដើមចោទអ្នកស្រី ទណខ បានទទួលដីកាកោះហើយៗ ពុំបានចូល រួមសវនាការនេះទេ ប៉ុន្តែមេធាវីបានចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុក ជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៤(ឈ) ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខ ចុងចម្លើយ និងមេធាវីដើមចោទ**

**កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ២០២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់លោកសអរ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៤(ឈ) ចុះថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០០០ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀល ដែលអ្នកស្រីទណខ បានបង់រួចហើយគឺ

ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥០០០រៀល សរុប១៩.០០០រៀល ។

បង្គាប់ឱ្យចុងចម្លើយអ្នកស្រីទណខ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤- សាលដីកានេះ ប្រកសេនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២ ។